**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៩-២០២០

**ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣**

**ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៩**

- *សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូអ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា !*

**ពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០១៩-២០២០** គឺចាប់ផ្តើមពី **ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១៩** នេះតទៅ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំព្រះករុណាខ្ញុំសូមសម្តែងនូវការអបអរសាទរ និងចូលរួមសប្បាយរីករាយ ជាមួយបងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ ក្មួយៗសិស្សានុសិស្សទាំងអស់គ្រប់ភូមិសិក្សា ដែលបាន និងកំពុងសស្រាក់សស្រាំរៀបចំខ្លួនអបអរសាទរថ្ងៃផ្តើមជីវិតសិក្សាដំបូងរបស់កូន ក្មួយចៅតូចៗ ដែលទើបនឹងដល់អាយុត្រូវចូលសាលារៀន និងជាថ្ងៃដែលក្មួយៗសិស្សានុសិស្ស- និស្សិតរបស់យើងបន្តចូលរៀនសូត្រនៅកម្រិតថ្នាក់ខ្ពស់បន្តទៀតនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងមនោសញ្ចេតនារីករាយកក់ក្តៅ និងមោទនភាពជាទីបំផុត ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ មាតាបិតា អាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍទាំងអស់ ដែលបានខិតខំប្រឹងប្រែងចូលរួមលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងធនធាន សម្រាប់ជួយជ្រោមជ្រែងលើគ្រប់សកម្មភាព ក្នុងបុព្វហេតុរួមចំណែកកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យទទួលបានជោគជ័យក្នុងរយៈពេលកន្លងមក ។

*- បងប្អូនជនរួមជាតិជាទីស្នេហា !*

ក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ បន្ទាប់ពីទទួលបានសុខសន្តិភាពពេញលេញនៅចុងឆ្នាំ ១៩៩៨ តាមរយៈការអនុវត្តនយោបាយ **«ឈ្នះ- ឈ្នះ»** កម្ពុជាសម្រេចបាននូវការអភិវឌ្ឍលើគ្រប់វិស័យគួរជាទីមោទនៈ ។ បច្ចុប្បន្នសុខសន្តិភាពបានគ្របដណ្តប់ពេញផ្ទៃប្រទេស កម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពានតភ្ជាប់គ្នាខ្វាត់ខ្វែងគ្រប់ច្រកល្ហក ប្រជាជនមានជីវភាពរស់នៅកាន់តែល្អប្រសើរ មានមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់ មានសិទ្ធិសេរីភាពជួបជុំក្រុមគ្រួសារដើរលេងកម្សាន្ត ទាំងក្នុង និងក្រៅប្រទេស ហើយបានចូលរួមប្រារព្ធគ្រប់ពិធីបុណ្យជាតិបានយ៉ាងទូលំទូលាយជាមួយនឹងភាពសប្បាយរីករាយជាមួយក្រុមគ្រួសារ និងញាតិមិត្ត ប្រកបដោយសុវត្ថិភាព និងភាពសុខដុមរមនាគ្រប់ជាតិសាសន៍នៅទូទាំងប្រទេស ។

ពេលនេះ រាជរដ្ឋាភិបាលបាន និងកំពុងខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចបន្តទៀត ដើម្បីឱ្យកម្ពុជាក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងទៅជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

**យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤** របស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា បានចាត់ទុកការអភិវឌ្ឍធនធានមនុស្ស គឺជាអាទិភាពទី ១ ជាមួយនឹងការប្តេជ្ញាសម្រេចឱ្យបាននូវមុំទី ១ គឺ **«ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា»** តាមរយៈការទាញយកប្រយោជន៍ពីកាលានុវត្តភាពនៅក្នុងតំបន់ការចាប់យកបច្ចេកវិទ្យា និងឱកាសថ្មីៗ ព្រមទាំងលើកកម្ពស់ការប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ ដើម្បីធានាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ។

ក្នុងស្មារតីនេះ កម្ពុជាបានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ ២០៣០ ឆ្ពោះទៅធានាគុណភាពអប់រំប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសំដៅធានាបាននូវសិទ្ធិសេរីភាព និងសុភមង្គលសម្រាប់បុគ្គល គ្រួសារ និងសង្គមជាតិ ។ ជាបន្តបន្ទាប់ រាជរដ្ឋាភិបាលបានខិតខំដោះស្រាយរាល់បញ្ហា និងសំណូមពរទាំងឡាយ ដើម្បីលើកកម្ពស់វិស័យអប់រំនៅកម្ពុជា បង្កើតធនធានមនុស្ស និងមូលធនបញ្ញា ទាំងអ្នកសិក្សា និងគ្រូបង្រៀនប្រកបដោយគុណភាព សមត្ថភាព ស្របតាមនិន្នាការរីកចម្រើន និងបទដ្ឋានអប់រំនៅក្នុងតំបន់ និងពិភពលោក ។

*- បងប្អូនជនរួមជាតិជាទីស្នេហា !*

**«ការអប់រំប្រកបដោយចីរភាព»** ពិតជាមានសារៈសំខាន់ ដើម្បីធានាការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន ដែលផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជា ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅទូទាំងប្រទេស ។

ដើម្បីលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត និង ធានាបាននូវការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្នសម្រាប់ទាំងអស់គ្នា ខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវដូចតទៅ ÷

**ទី១.** ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ត្រូវរួមគ្នាពិនិត្យឡើងវិញនូវគោលនយោបាយ ក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការចាំបាច់ ដើម្បីដឹកនាំ គ្រប់គ្រង និងអនុវត្តឱ្យមានប្រសិទ្ធភាព និងធានាបាននូវការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្នសម្រាប់សិស្សានុសិស្សគ្រប់រូប ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ។ ត្រូវបង្កើនប្រសិទ្ធភាព ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសម្រាប់គ្រឹះស្ថានសិក្សា ការពង្រាយគ្រូបង្រៀនឱ្យបានដល់គ្រប់សាលារៀន និងការបន្តអភិវឌ្ឍសមត្ថភាពនាយកសាលា និងគ្រូបង្រៀន នៅតាមគ្រឹះស្ថានបណ្តុះបណ្តាល និងគ្រឹះស្ថានសិក្សា ជាពិសេសការពង្រឹងការងារអធិការកិច្ច និងយន្តការពិនិត្យកែលម្អជាប្រចាំ ។

**ទី២.** គ្រឹះស្ថានសិក្សាគ្រប់កម្រិត រួមទាំងទីវត្តអារាម ត្រូវផ្តល់លទ្ធភាពក្នុងការអប់រំពេញលេញ និងមានគុណភាព តាមរយៈការបង្កើនការផ្សព្វផ្សាយ ការធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន និងត្រៀមលក្ខណៈតាមគ្រប់រូបភាព ដូចជាអាកាសធាតុក្តៅហួតហែង ទឹកជំនន់ ខ្យល់កន្ត្រាក់ ។ ល ។ គ្រឹះស្ថានសិក្សាត្រូវធានារយៈពេលនៃការរៀន និងបង្រៀនឱ្យបានពេញលេញស្របតាមកម្មវិធីសិក្សាដែលបានកំណត់ ។ គ្រឹះស្ថានសិក្សាត្រូវខិតខំពង្រីកសក្តានុពលរបស់ខ្លួនដើម្បីឱ្យក្លាយទៅជាសាលាកុមារមេត្រីកម្រិតអភិវឌ្ឍ និងប្រែក្លាយខ្លួនទៅជាសាលារៀនជំនាន់ថ្មីសម្រាប់បង្កើតធនធានមនុស្ស មានជំនាញខ្ពស់លើមុខវិជ្ជា**វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម** និង**គណិតវិទ្យា** ។

**ទី៣.** លោកគ្រូ អ្នកគ្រូត្រូវរួមគ្នាបន្តដើរតួជាបុគ្គលគំរូ ជាឪពុកម្តាយ ជាមគ្គុទេសក៍ អ្នកស្រាវជ្រាវ ជាទីប្រឹក្សា និងជាអ្នកនាំមកនូវគំនិតច្នៃប្រឌិត តាមរយៈការខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពខ្លួនជាប្រចាំ ទាំងផ្នែកចំណេះដឹង និងវិធីសាស្ត្របង្រៀន រួមទាំងបច្ចេកវិទ្យាព័ត៌មាន ភាសាបរទេស ការសិក្សាស្រាវជ្រាវ ដើម្បីយកចំណេះដឹងថ្មីៗមកបង្ហាត់បង្រៀនសិស្សឱ្យមានចំណេះដឹងទូលំទូលាយ អភិវឌ្ឍខ្លួនទៅជាពលរដ្ឋសកល និងជាអ្នកបន្តវេនសម្រាប់ថ្ងៃអនាគត ។ ជាមួយគ្នានេះ គ្រប់ប្រព័ន្ធអប់រំត្រូវរួមគ្នាអនុវត្ត ប្រកបដោយប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។

**ទី៤.** កូនៗជាសិស្សានុសិស្ស និងយុវជនយុវនារីទាំងអស់ត្រូវខិតខំរៀនសូត្រឱ្យបានខ្ជាប់ខ្ជួន ត្រូវចូលរួមឱ្យបានគ្រប់សកម្មភាព ដើម្បីគាំទ្រដំណើរការអភិវឌ្ឍសាលារៀន និងសង្គមជាតិយើង ។ កូនៗសិស្សានុសិស្សទាំងអស់ត្រូវចងចាំថា បើយើងស្រឡាញ់ខ្លួនយើង ស្រឡាញ់ឪពុកម្តាយ និងស្រឡាញ់អនាគតរុងរឿង កូនៗត្រូវនៅឱ្យឆ្ងាយពីគ្រឿងញៀន ត្រូវចេះណែនាំមិត្តភក្តិអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ព្រមទាំងត្រូវចៀសវាងឱ្យបាននូវការប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ។ កូនៗត្រូវប្រតិបត្តិច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ត្រូវចេះយោគយល់ និងអធ្យាស្រ័យគ្នា ក្នុងពេលធ្វើដំណើរ ដើម្បីធានាបាននូវសុវត្ថិភាពផ្ទាល់ខ្លួនផង និងអ្នកដទៃផង ក៏ដូចជារក្សាបាននូវសេចក្តីថ្លៃថ្នូរដល់សង្គមជាតិយើង ។

**ទី៥.** ជនរួមជាតិទាំងអស់ មាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសហគមន៍ ត្រូវនាំគ្នាបញ្ជូនកូនចៅទៅចុះឈ្មោះចូលរៀននៅដើមបវេសនកាលឆ្នាំសិក្សាថ្មីនេះឱ្យបានគ្រប់ៗគ្នា និងត្រូវយកចិត្តទុកដាក់តាមដានការសិក្សារបស់កូនចៅឱ្យបានជាប្រចាំ ។ សូមបង្កើតបរិយាកាសល្អក្នុងក្រុមគ្រួសារ ក៏ដូចជាការផ្តល់ដំបូន្មានដល់កូនចៅ ទាំងផ្នែកសុខភាព ចំណេះដឹង និងសីលធម៌ ដើម្បីជួយឱ្យពួកគេក្លាយជាធនធានមនុស្សពោរពេញដោយសមត្ថភាព ទេពកោសល្យ ព្រមទាំងទទួលបានសម្បទាសម្រាប់ការចាប់យកវិជ្ជាបំណិន និងចរិយាឈានទៅកសាងអនាគតដ៏រុងរឿង ស័ក្តិសមជាកុលបុត្រខ្មែរ និងជាសសរទ្រូងនៃប្រទេសជាតិយើង ។

**ទី៦.** អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រមទាំងសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេស ត្រូវរួមគ្នាយកចិត្តទុកដាក់ចូលរួមគាំទ្របន្ថែមទៀត ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការគាំទ្រផ្សេងៗទៀតតាមគ្រប់លទ្ធភាព ។ ត្រូវបង្កលក្ខណៈដល់សិស្ស និងយុវជនដែលមិនបានរៀនសូត្រ ឬ បោះបង់ការសិក្សាឱ្យមានឱកាសបានការរៀនសូត្រជាថ្មី ជាពិសេសត្រូវខិតខំបង្កលក្ខណៈងាយស្រួលដល់សិស្ស និងយុវជនដែលមានពិការភាពឱ្យទទួលបានលទ្ធភាពក្នុងការសិក្សារៀនសូត្រយ៉ាងតិច ៩ ឆ្នាំ និងគាំទ្រឱ្យពួកគេបានបន្តរៀនសូត្រចប់ភូមិសិក្សា និងរហូតដល់ចប់កម្រិតឧត្តមសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

**ទី៧.** ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរួមគ្នាបង្កើនកិច្ចសហការ និងពង្រឹងភាពជាដៃគូកាន់តែរឹងមាំ និងមានប្រសិទ្ធភាពថែមទៀត ក្នុងការជួយឧបត្ថម្ភគាំទ្រដល់សិស្សជួបការលំបាក និងកម្មវិធីអប់រំនានាដែលស្ថិតនៅតំបន់ដាច់ស្រយាល និងកន្លែងដែលសេវាអប់រំពិបាកទៅដល់ ។

**ទី៨.** ប្រព័ន្ធផ្សព្វផ្សាយទាំងអស់នៅកម្ពុជា រួមមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋ និងឯកជន ត្រូវរួមគ្នាជួយផ្សព្វផ្សាយ និងបញ្ជ្រាបឱ្យបានកាន់តែទូលំទូលាយអំពីសារៈសំខាន់នៃការអប់រំ ព្រមទាំងអំពាវនាវដល់មាតាបិតា អាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធបានជ្រួតជ្រាបចូលរួមលើកកម្ពស់វិស័យអប់រំនៅកម្ពុជា និងនាំកូនដល់អាយុមកចុះឈ្មោះចូលរៀនឱ្យបានគ្រប់ៗគ្នា ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ សូមអរគុណចំពោះបងប្អូនជនរួមជាតិ លោកគ្រូអ្នកគ្រូ បុគ្គលិកអប់រំ សាស្ត្រាចារ្យទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជននានាដែលតែងតែបានរួមចំណែកកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការរីកចម្រើនគួរជាទីមោទនៈ ទាំងពេលកន្លងមក និងបច្ចុប្បន្ន និងសូមជួយឧបត្ថម្ភគាំទ្រ និងផ្តល់នូវកិច្ចសហការល្អបន្តទៀត ដើម្បីឱ្យយុវជនកម្ពុជាជំនាន់ក្រោយក្លាយជាធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាពខ្ពស់ ចូលរួមចំណែកការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចជាតិយើងឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់វិស័យ ។

ជាទីបញ្ចប់ ក្នុងឱកាស**បើកបវេសនកាលឆ្នាំសិក្សា ២០១៩-២០២០** នេះ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរបងប្អូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោក គ្រូអ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមប្រកបដោយពុទ្ធពរ និង ពរទាំង ៥ ប្រការ គឺ ***អាយុ វណ្ណៈ សុខៈ ពលៈ*** និង ***បដិភាណៈ*** កុំបីឃ្លៀងឃ្លាតឡើយ ៕

*ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**